អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# អនុស្សរណៈអន្តរការិយាល័យ
# INTEROFFICE MEMORANDUM

**ផ្ញើពី/From:** **ប្រធានអង្គជំនុំជម្រះតុលាការកំពូល („ប្រធាន")**
**President of the Supreme Court Chamber (the "President")**

ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥
Date: 19 November 2015

**ផ្ញើជូន/To:** **អង្គភាពគាំពារការការពារក្ដី**
**Defence Support Section ("DSS")**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2015, 17:47
CMS/CFO: Sann Rada

**ចម្លងជូន/CC:** **ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល, ភាគីនៃសំណុំរឿង ០០២**
**Judges of the Supreme Court Chamber;**
**Parties to Case 002**

**កម្មវត្ថុ/Subject:** **ការអនុវត្តន៍តាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្ដី នួន ជា**
**Follow-up to Supreme Court Chamber's Instruction to Appoint Standby Counsel for NUON Chea**

យោងតាមសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដែលបានណែនាំអង្គភាពគាំពារការការពារក្ដីឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្ដី នួន ជា ឱ្យបានឆាប់ដែលអាចធ្វើទៅបាន។ អនុស្សរណៈនេះ មានគោលបំណងបញ្ជាក់លម្អិតទៅលើសេចក្ដីណែនាំដែលបានផ្ដល់ជូនអង្គភាពគាំពារការការពារក្ដី ដើម្បីធានាដល់ការចាត់តាំងនេះឱ្យបានពេញលេញ និងឆាប់រហ័ស។

យើងរំលឹកថា អង្គជំនុំជម្រះយល់ឃើញថា ក្របខ័ណ្ឌផ្នែកច្បាប់ដែលអនុវត្តចំពោះកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក បញ្ជាក់ថា នៅពេលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ជនជាប់ចោទនៅក្នុងករណីបទឧក្រិដ្ឋ ត្រូវតែទទួលបានជំនួយពីមេធាវី និងថា មេធាវីការពារក្ដីជនជាប់ចោទ ត្រូវតែ

ការពារនៅក្នុងបន្ទប់សវនាការពេញអំឡុងពេលនៃសវនាការបណ្តឹងសាទុក្ខ ដោយឯករាជ បើទោះបីអាចផ្ទុយពីបំណងប្រាថ្នារបស់ជនជាប់ចោទក៏ដោយ។

នៅពេលសវនាការកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សហមេធាវីជាតិការពារក្តី នួន ជា លោក សុន អរុណ ដែលជាសហមេធាវីតែម្នាក់គត់ បានការពារ នួន ជា នៅពេលសវនាការ ហើយបានបោះបង់ចោលបន្ទប់សវនាការ បើទោះបីជាមានការណែនាំបញ្ជាក់ម្តងហើយម្តងទៀតយ៉ាងច្បាស់ និងដោយផ្ទាល់ថា មេធាវីត្រូវបន្តមានវត្តមានក៏ដោយ។ ការអវត្តមានរបស់គាត់ បានរារាំងដល់សវនាការបណ្តឹងសាទុក្ខ មិនឱ្យបន្តតាមអ្វីដែលបានគ្រោងទុក ដោយធ្វើឱ្យអង្គជំនុំជម្រះ គ្មានជម្រើសក្រៅតែពីផ្អាកកិច្ចដំណើរការនីតិវិធីឡើយ។ ដោយសារតែមានការប្រព្រឹត្តរបស់លោក សុន អរុណ និងដើម្បីជៀសវាងការផ្អាកបន្ថែមទៀតនាពេលអនាគត អង្គជំនុំជម្រះសម្រេចបង្គាប់ឱ្យមានការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្តី នួន ជា ដោយហេតុថា ប្រសិនបើ ជនជាប់ចោទមានកង្វះជំនួយផ្នែកច្បាប់សមស្របនៅពេលដែលសវនាការបន្តនោះ ជំនួយនៅក្នុងតុលាការដែលត្រូវតែមានជាដាច់ខាតនេះ អាចនឹងត្រូវបានផ្តល់ភ្លាមដោយមេធាវីដែលត្រូវបានចាត់តាំងដោយតុលាការ។

តួនាទីរបស់មេធាវីត្រៀមបម្រុង ពុំមែនត្រូវជំនួសមេធាវីដែលត្រូវបានជ្រើសរើសការពារក្តី នួន ជា នោះទេ។ មេធាវីបម្រុង ត្រូវទទួលខុសត្រូវចំពោះការត្រៀមរៀបចំ និងធានាលទ្ធភាពទទួលបន្ទុកការការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីដែលសហមេធាវីជាតិ និងអន្តរជាតិការពារក្តី នួន ជា អវត្តមាននៅក្នុងបន្ទប់សវនាការ នៅពេលដែលសវនាការត្រូវបន្ត ឬអវត្តមានអំឡុងពេលនៃសវនាការទាំងមូល។ អាស្រ័យហេតុនេះ មេធាវីបម្រុង ត្រូវតែចូលរួមសវនាការបណ្តឹងសាទុក្ខទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ ត្រូវតែឯករាជពីក្រុមមេធាវីបច្ចុប្បន្នការពារក្តី នួន ជា និងពុំត្រូវពិគ្រោះពិភាក្សា ឬទទួលការណែនាំពី នួន ជា លើកលែងតែមានការបង្គាប់ពីអង្គជំនុំជម្រះតុលាការកំពូល។ បន្ទាប់ពីមានសំណើសុំសមហេតុផល មេធាវីបម្រុង នឹងត្រូវបានផ្តល់ឱ្យនូវពេលវេលាគ្រប់គ្រាន់ ក្នុងការស្វែងយល់នូវសំណុំរឿងដោយខ្លួនឯងជាមួយនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ សារណាបណ្តឹងសាទុក្ខនីមួយៗរបស់ នួន ជា និង ខៀវ សំផន សារណាតបនីមួយៗរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាផងដែរ។ មេធាវីបម្រុង ពុំត្រូវបានប្រគល់សិទ្ធិឱ្យការពារក្តី នួន ជា រហូតទាល់តែអង្គជំនុំជម្រះនេះ បានបង្គាប់ឱ្យមេធាវីធ្វើដូច្នោះ។

យើងពិចារណាឃើញថា តួនាទីនេះ គឺសក្តិសមសម្រាប់មេធាវីជាតិ ដែលត្រូវជ្រើសតាំងចេញពីបញ្ជីឈ្មោះមេធាវី ដោយអនុលោមតាមវិធាន ១១(២)(ឃ)(១) នៃវិធានផ្ទៃក្នុង ដែលមានការយល់ដឹងនូវកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

យើងណែនាំថា អង្គភាពគាំពារការការពារក្តី ត្រូវរៀបចំនីតិវិធីនៃការចាត់តាំងនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងថា អង្គភាពគាំពារការការពារក្តី ត្រូវរាយការណ៍មកកាន់អង្គជំនុំជម្រះតុលាការកំពូលរៀងរាល់សប្តាហ៍នូវការវិវឌ្ឍន៍ នៅក្នុងការអនុវត្តន៍នៃសេចក្តីណែនាំនេះពាក់ព័ន្ធនឹងការចាត់តាំងមេធាវីត្រៀមបម្រុងនេះ ដោយផ្តល់នូវរបាយការណ៍លើកដំបូងនៅថ្ងៃ អង្គារ ទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥។

យើងណែនាំបន្ថែមទៀតថា ការិយាល័យរដ្ឋបាលត្រូវផ្តល់ការគាំទ្រណាមួយដែលចាំបាច់ ឱ្យមានប្រសិទ្ធិដល់សេចក្តីណែនាំចាត់តាំងមេធាវីត្រៀមបម្រុងនេះ។

Reference is made to the Supreme Court Chamber's oral decision of 17 November 2015, in which it instructed the DSS to appoint standby counsel for NUON Chea as soon as possible. The purpose of the present Memorandum is to further detail the instructions given to the DSS, in order to ensure an adequate and expeditious fulfillment thereof.

I wish to recall that it is this Chamber's view that the legal framework applicable to proceedings before the ECCC indicates that, when appearing before the Supreme Court Chamber, an accused in a case involving a felony must be assisted by a lawyer, and that, therefore, a lawyer for the accused must be present in the courtroom throughout the appeal hearing, independent of the accused person's possible wishes to the contrary.

At the appeal hearing held on 17 November 2015, National Co-Lawyer for NUON Chea, Mr SON Arun – who was the only Co-Lawyer representing NUON Chea at the hearing – abandoned the courtroom, in spite of this Chamber's clear, direct and reiterated instruction to remain present. His absence prevented the appeal hearing from continuing as scheduled, leaving this Chamber no choice but to adjourn proceedings. In light of Mr SON Arun's conduct and in order to avoid future adjourments, the Chamber decided to order the appointment of a standby counsel for NUON Chea, so that, should the Accused be lacking proper legal assistance when appeal hearings resume, such mandatory in-court assistance may be provided by a court-appointed lawyer.

The role of the standby counsel will not be that of replacing NUON Chea's chosen lawyers. His or her responsibility will be to prepare and maintain capacity to take over the defence of NUON Chea during the appeal hearings before the Supreme Court Chamber, should NUON Chea's International and National Co-Lawyers fail to be present in the courtroom when the hearings resume, or absent themselves in the course of the hearings. Accordingly, standby counsel shall attend all appeal hearings in Case 002/01, shall be independent of the present Defence team for NUON Chea and shall not consult with, or take direction from, NUON Chea, unless so ordered by this Chamber. Standby counsel will, upon reasoned request, be granted adequate time to familiarise him or herself with the case, with particular reference to

the judgment of the Trial Chamber in Case 002/01, NUON Chea's and KHIEU Samphân's respective appeal briefs, the Co-Prosecutors' and Civil Party Lead Co-Lawyers' respective responses, as well as the Co-Prosecutors' appeal brief. Standby counsel will not be granted a right of audience until this Chamber has directed him or her to take over the defence of NUON Chea.

I envisage that this role would be better served by a national lawyer, assigned from the list mentioned under Internal Rule 11(2)(d)(i), preferably demonstrating an established familiarity with proceedings before the ECCC.

I direct that DSS conduct this appointment process as expeditiously as possible and that the DSS report to the Supreme Court Chamber on a weekly basis the progress in the enactment of its instructions regarding appointment of standby counsel, with the first report due on Tuesday, 1 December 2015.

I further direct the Office of the Administration to provide any such support as needed to give effect to the Chamber's instructions to appoint standby counsel.